## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## សេចក្តីប្រកាសព័ត៌មាន

លេខ: 30 PR-23/EoJ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

# ការចាប់ផ្តើមទទួលពាក្យសុំចូលរួម
# ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជាលើកទី១២
# សម្រាប់មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយជម្រាបជូនថា ស្ថានទូតរួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំនូវ **ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជាលើកទី១២** (ការប្រកួតផលិតរឿងខ្លីសម្រាប់សិស្សវិទ្យាល័យ) ក្រោមប្រធានបទ «**អ្វីដែលខ្ញុំចង់បាន (What I want)**» ដើម្បីជ្រើសរើសក្រុមសិស្សដែលមានស្នាដៃផលិតរឿងល្អចំនួន៣ក្រុម ទៅចូលរួម «**មហាស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០២៣**» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ធ្នូ ឆ្នាំ២០២៣ នៅទីក្រុង មិណាមិអាវ៉ាជិ ខេត្តហ្យូហ្គុ ប្រទេសជប៉ុន។

កម្មវិធីលម្អិតមានដូចខាងក្រោម៖

- បទបង្ហាញណែនាំចូលរួមប្រកួតផលិតរឿងខ្លីសម្រាប់សិស្សវិទ្យាល័យ **ថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០២៣ ម៉ោង ១៤:០០នាទី** នៅបន្ទប់លេខ៩ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ឬតាមZoom

  (សូមធ្វើការចុះឈ្មោះជាមុន៖ https://forms.office.com/r/HcJdxhikbQ)
- ផុតកំណត់ការទទួលពាក្យ និងទទួលរឿងខ្លី **ថ្ងៃព្រហស្បតិ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២៣ ត្រឹមម៉ោង ៤.៣០រសៀល** តាមរយៈMicrosoft Form (ពាក្យសុំចូលរួម៖ https://forms.office.com/r/6UAWJhLNKm)

- ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា នឹងប្រព្រឹត្តិទៅនៅ**ថ្ងៃចន្ទ ទី០៩ ខែតុលា ឆ្នាំ ២០២៣ វេលាម៉ោង២រសៀល** នៅ CJCC

យើងខ្ញុំ សូមស្វាគមន៍សិស្សវិទ្យាល័យថ្នាក់ទី១០ និងទី១១ ក្នុងឆ្នាំ២០២២-២០២៣ ទាំងអស់ ដើម្បីចូលរួមប្រកួតផលិតរឿងខ្លីនេះ។ ពាក្យចូលរួមអាចរកបានតាមរយៈគេហទំព័រស្ថានទូតជប៉ុន៖ https://www.kh.emb-japan.go.jp/itpr_en/00_000145.html ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរសព្ទលេខ ០២៣ ២១៧ ១៦១ (១១២១) ឬ អ៊ីម៉ែល info.jpn@pp.mofa.go.jp ។

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*លេខទំនាក់ទំនង*: 023 217 161
*អ៊ីម៉ែល*: info.jpn@pp.mofa.go.jp,
*គេហទំព័រផ្លូវការ*: www.kh.emb-japan.go.jp